ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ជម្ងឺបូសខ្យល់



នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម
នាយកដ្ឋានផលិតកម្ម និងបសុពេទ្យាបាល
កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម ASDP, ADB
Loan 2022-CAM{SF}
ឆ្នាំ 2010





ការផ្សាយរបស់ក្រុមការងារផ្សព្វផ្សាយបច្ចេកវិទ្យាកសិកម្ម
កម្មវិធីអភិវឌ្ឍន៍វិស័យកសិកម្ម ASDP, ADB
Loan 2022-CAM{SF}
ឆ្នាំ 2010

## ឯកសារយោង:


- របាយការណ៍បូកសរុបលទ្ធផលការងារផលិតកម្ម និងបសុព្យាបាលប្រចាំឆ្នាំ ២០០៦-២០០៧ , ឆ្នាំ ២០០៧-២០០៨ របស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
- យុទ្ធសាស្ត្រអភិវឌ្ឍវិស័យចិញ្ចឹមសត្វនៅកម្ពុជា ដោយវិទ្យាស្ថាន ជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម រាជបណ្ឌិត សភា ឆ្នាំ ២០០៨
- បទបង្ហាញ ស្តីពីការយកវត្ថុវិភាគរបស់លោកស្រី រ៉េន ធារី មន្ត្រីវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល, នាយកដ្ឋាន ផលិតកម្ម និងបសុព្យាបាលថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩
- បទបង្ហាញស្តីពីការពង្រឹងលើការអនុវត្តលិខិតបទដ្ឋាននៃ អនុក្រឹតលេខ ២៦អនក្រ.បកចុះថ្ងៃទី ០២ មីនា ឆ្នាំ ២០០១ ស្តីពីការបង្កើត និងគ្រប់គ្រងភ្នាក់ងារសុខភាពសត្វភូមិ របស់លោក ពេច ប៉េដា (២៤/០៣/០៩)
- ខិតប័ណ្ណស្តីពីអត្ថប្រយោជន៍នៃការចាក់ថ្នាំការពារជំងឺបូសខ្យល់ របស់នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល
- ខិតប័ណ្ណជំងឺបូសខ្យល់ ការិយាល័យផ្សព្វផ្សាយបច្ចេកទេសផលិតកម្ម និងបសុព្យាបាល នៃនាយកដ្ឋានផលិតកម្ម និងបសុព្យាបាលសហការជាមួយ HPI
- សៀវភៅបណ្តុះបណ្តាលពេទ្យសត្វភូមិ ន.ផ.ប ភ្នំពេញ ២០០០
- ឯកសារស្តីពីជំងឺឆ្លងបង្រៀនដោយលោក ផេង សុខាំ
- សារណាបញ្ចប់ការសិក្សា ស្តីពី ជំងឺឆ្លងដែលជួបប្រទះញឹកញាប់ លើសត្វពាហនៈ ក្នុងខេត្តបន្ទាយមានជ័យ របស់លោក ហាស់ ពិសិទ្ធ និស្សិត ជំនាន់ទី ៦ ឆ្នាំ ១៩៩៥ ទំព័រ ទី ២៨-៣២, ៧៥-៧៦
- ឯកសារបណ្តុះបណ្តាលពេទ្យសត្វភូមិមណ្ឌលទី ២ របស់អង្គការ CWS
- សារណាបញ្ចប់ការសិក្សា ឆ្នាំ ១៩៩២ របស់និស្សិត ម៉ក់ សុគឌី ស្តីពី វិធានការបំបាត់ជំងឺឆ្លងសំខាន់ៗ នៃ សត្វគោ-ក្របី នៅខេត្តកណ្តាល
- ស្ថានភាពជំងឺបូសខ្យល់កើតមានឡើងចំពោះគោ និង ក្របីនៅកម្ពុជា ដោយអ្នកស្រី Kate O' Sullivan 1994






# ជម្ងឺបូសខ្យល់

Blackleg

## ១-សេចក្តីផ្តើម:

ជម្ងឺបូសខ្យល់ជាជំងឺឆ្លងបង្កឡើងដោយបាក់តេរី ឈ្មោះClostridium Chauvoei ដែលបង្កើតជាស្ព័រនៅក្នុង និងក្រៅសារពាង្គកាយ ។ កើតនៅលើពពួកសត្វទំពាអៀងមានដូចជាគោ ក្របី ចៀម និងពពែ។ ចំពោះជ្រូកកំរកើតជម្ងឺនេះណាស់ ។ ជម្ងឺនេះច្រើនកើតមាននៅដោយតំបន់ ជាពិសេសកើតនៅរដូវភ្លៀងធ្លាក់ដែលបណ្តាលឱ្យសត្វស្លាប់យ៉ាងឆាប់រហ័ស។ ជំងឺនេះបណ្តាលមកពីបាក់តេរី Clostridium Chauvoei ដែលបង្កើតជាស្ព័រ ហើយស្ព័រធន់នឹងកំដៅ អាចរស់នៅបានយូរឆ្នាំក្នុងដី

- ក្នុងលក្ខខណ្ឌសមស្របវារស់នៅជាមធ្យមបានពី ៤-៥ ឆ្នាំ ឬ អាចរហូតដល់ ១១ ឆ្នាំក៏មាន
- នៅក្នុងសាច់ធ្វើងៀតវារស់នៅយ៉ាងតិចបាន ៨ ឆ្នាំ
- នៅក្នុងសាច់ប្រឡាក់អំបិលនៅបាន ២ ឆ្នាំ
- ក្នុងសម្ភារ ឬ ពំនូកសំរាមស្អុយរលួយវារស់នៅបាន ៦ ខែ ។

តាមការសង្កេតរបស់អ្នកសិក្សាស្រាវជ្រាវពីជម្ងឺបូសខ្យល់បានឱ្យ

ដឹងថាជម្ងឺនេះហាក់ដូចជាស្ថិតនៅតែមួយកន្លែងក្នុងតំបន់ ហើយការកើតចេញនៃជម្ងឺនេះកើតមានឡើងដោយសារដីមានមេរោគដែលបណ្តាលមកពីលាមក ឬខ្មោចសត្វដែលស្លាប់ដោយជំងឺនេះ ។ បាក់តេរី Clostridium Chauvoei គឺជាបាក់តេរីដែលត្រូវបានគេរកឃើញនៅក្នុងថ្លើម ផាល និងប្រព័ន្ធរំលាយអាហាររបស់សត្វពាហនៈដែលមានសុខភាពល្អ ។

## ២. ការចម្លង និងការរាលដាលៈ

ជម្ងឺបូសខ្យល់ឆ្លងពីសត្វមួយទៅសត្វមួយតាមរយៈការប៉ះពាល់ផ្ទាល់ជាមួយសត្វឈឺ មេរោគជម្ងឺបូសខ្យល់ចូលទៅក្នុងខ្លួនសត្វតាមរយៈការប៉ះពាល់ស្ព័រដែលមាននៅលើសាកសពសត្វ ផលិតផលសត្វឈឺ លើដី លើស្មៅ ក្នុងទឹក ឬតាមរយៈមុខរបួសផ្សេងៗ ។ ជាទូទៅមេរោគនៃជម្ងឺបូសខ្យល់ឆ្លងចូលទៅក្នុងខ្លួនសត្វតាមពីររបៀបៈ

**តាមផ្លូវអាហារៈ** មេរោគចូលទៅក្នុងខ្លួនសត្វនៅពេលដែលស៊ីស្មៅ ផឹកទឹកដែលមានជាប់មេរោគ មេរោគនោះក៏បន្តជ្រៀតតាមភ្នាសពោះវៀន រួចចូលទៅក្នុងឈាម ។ តាមឈាមមេរោគបន្តចូលទៅក្នុងសាច់ដុំ ។

**តាមមុខរបួស ៈ** មេរោគនឹងជ្រៀតចូលតាមស្នាមរបួសដែលមាននៅលើខ្លួនសត្វ ។ ការធ្វើឱ្យជាំ ឬការបំផ្លាញសាច់ដុំអាចធ្វើឱ្យសត្វកាន់តែងាយទទួលជម្ងឺនេះ។





**នៅពេលដែលសត្វមានជំងឺត្រូវៈ**

- បំបែកសត្វឈឺចេញពីហ្វូង
- ធ្វើអនាម័យកន្លែងចិញ្ចឹមសត្វជាប្រចាំ
- ជៀសវាងផ្តល់ចំណីដូចជា ស្មៅ រុក្ខជាតិមានប្រភពពីកន្លែងកើតជំងឺ ឬ ឆ្លងជំងឺ
- ហាមចលនាសត្វចេញ–ចូល ឬឆ្លងកាត់តំបន់កើតជំងឺ
- ហាមទិញ–លក់សត្វគ្រប់ប្រភេទ ដែលមានជំងឺផ្ទុកមេរោគ ឬ ឆ្លងជំងឺ និងពិឃាដយកសាច់ធ្វើជាម្ហូប
- សត្វស្លាប់ដោយជំងឺបូសខ្យល់ត្រូវដុតចោល ឬកប់ក្នុងរណ្តៅដែលមានជំរៅយ៉ាងតិចជម្រៅ ២ ម៉ែត្រ

**ការព្យាបាលៈ**

ក្នុងករណីដែលជំងឺស្ថិតនៅក្នុងស្ថានភាពមិនធ្ងន់ធ្ងរ ត្រូវប្រើអង់ទីប៊ីយូទិចអាចទទួលលទ្ធផលល្អ ។ ប៉ុន្តែភាគច្រើនគេពិនិត្យឃើញថាជាការហួសពេលក្នុងការព្យាបាលជំងឺបូសខ្យល់ឱ្យបានជាសះស្បើយ ។ ទោះបីសត្វជាសះស្បើយក្តីក៏សាច់ដុំដែលត្រូវបំផ្លាញមិនងាយត្រឡប់មកភាពដើមវិញ។




ថ្នាំការពារសត្វសម្រាប់ប្រឆាំងនឹងជំងឺបូសខ្យល់

## ៤. វិធានការការពារ

ត្រូវចាក់ថ្នាំការពារសត្វគោ-ក្របី ឱ្យបានទៀងទាត់តាមប្រតិទិនចាក់ថ្នាំការពារ ។ ជាពិសេសចំពោះសត្វជំទង់ៗត្រូវចាក់ឱ្យបានពីរដងក្នុងមួយឆ្នាំ ។

- លើកទី១ : ចាក់នៅអាយុពី ២-៦ ខែ
- លើកទី២: ចាក់នៅក្រោយពេលចាក់លើកទី១បានពី២-៤អាទិត្យ បន្ទាប់មកត្រូវចាក់ទៀងរាល់មួយឆ្នាំម្តង។





## ៣. រោគសញ្ញា:

ជម្ងឺបូសខ្យល់ច្រើនកើតមានឡើងនៅលើគោដែលមានអាយុចន្លោះពី ៣ ខែ ទៅ ៣ ឆ្នាំ ប៉ុន្តែជួនកាលសត្វដែលមានអាយុតិចជាង ឬច្រើនជាងក៏អាចកើតមានជំងឺនេះដែរ ប្រសិនបើវាស្ថិតនៅក្នុងហ្វូងជាមួយគ្នា ភាគច្រើនសត្វងាប់ដោយគ្មានបញ្ចេញរោគសញ្ញាអ្វីឡើយ ។ ក្នុងករណីមានរោគសញ្ញាសត្វនឹងបង្ហាញនូវរោគសញ្ញាដូចខាងក្រោម :



ស្នាមជាំឈាមខ្មៅនៅលើស្រទាប់ភ្នាសក្រោមស្បែក

- សត្វមានអាការៈឡើងកំដៅ កំលាំងចុះខ្សោយ ពិបាកដកដង្ហើម ជីពចរដើរញាប់ និងពិបាកធ្វើចលនា
- មិនស៊ីចំណី

– ដំណើរពិការអាស្រ័យទៅនឹងកន្លែងដែលទទួលរងនូវការរាតត្បាត

– សត្វមានការហើមនៅតាមសាច់ដុំដូចជាសាច់ដុំស្មា ត្រគាកទ្រូង និងខ្នង។ ពេលយើងយកម្រាមដៃទៅពាល់ត្រង់កន្លែងហើមនោះ ស្នាមជាំឈាមខ្មៅនៅលើស្រទាប់ភ្នាសក្រោមស្បែកយើងសង្កេតឃើញថា ដំបូងក្តៅបន្ទាប់មកក៏ត្រជាក់ ហើយសត្វមានការឈឺចាប់ ។ នៅពេលដែលជាលិកាសាច់ដុំស្លាប់ ភាពឈឺចាប់ និងកំដៅក៏ចុះថយដែរ បើយើងចុចត្រង់កន្លែងពកហើមនោះយើងនឹងលឺសូរក្រិបក្រៀបដែលបណ្តាលមក



ស្នាមជាំឈាមនៅលើសាច់ដុំ







ស្នាមជាំឈាមនៅលើសាច់ដុំ

ពីមានខ្យល់នៅក្រោមស្បែកត្រង់កន្លែងហើមនោះ ។ នៅលើមុខកន្លែងដុំហើមមានឡើងពណ៌ខ្មៅស្ងួតហើយមានក្លិនជូរ។ ម្យ៉ាងទៀត ក្រពេញកូនកណ្តុរនៅក្បែរៗនោះក៏រីកឡើងធំដែរ ។ សត្វឡើងកំដៅ ៤០–៤១ អង្សារសេ ដកដង្ហើមដាច់ៗរហូតដល់សីតុណ្ហភាពចុះនាំឱ្យសត្វងាប់ក្នុងរយៈពេល ២–៣ ថ្ងៃ។